**អេសឌីអូធី(SDOT) ចាប់ផ្តើមដំណើការទទួលពាក្យស្នើរសុំ
សំរាប់ប្រជាជនដែលត្រូវការប្រើស្ពាន ស្ពូខេន អេសធី ស្វីង
ដើម្បីអាចធ្វើការណាត់ជួបចាំបាច់សំរាប់ការជួយសង្គ្រោះជីវិត
នៅពេលដែលស្ពានស៊ីអាថូខាងលិចកំពុងស្ថិតក្នុងការសាងសង់**

*ការដាក់ពាក្យនិង*

*ចាប់ផ្តើមនៅខែបន្ទាប់នេះសំរាប់ភោជនីយដ្ឋាននិងហាងតវ៉ាន់លក់រាយដែលកំពង់តែជួបវិ*

*បត្តិ ជំងឺរាតត្បាត គ្រូពេទ្យប្រចាំការតាមទូរស័ព្ទ ប្រភេទយានយន្តបន្ថែម*

*រថយន្តច្រើនកៅអ៊ីនិងរថយន្តដឹកអ្នកដំណើរ។*

*ចុងសប្តាហ៍ម៉ោងជិះចូលគឺត្រូវបានពន្យារពេល៣ម៉ោងគឺដល់ម៉ោង៨ព្រឹក។*

ស៊ីអាថូ - ប្រជាជនកំពុងតែស្វែងរក ការព្យាបាលសំរាប់ការថែទាំសុខភាពសង្គ្រោះជីវិត គ្រូពេទ្យប្រចាំការតាមទូរស័ព្ទ ភោជនីយដ្ឋាននិងហាងតវ៉ាន់លក់រាយទាំងឡាយ នៅវេសស៊ីអាថូ  និងប្រជាជនដែលប្រើប្រាស់ឡានច្រើនកៅអ៊ី រថយន្តដឹកអ្នកដំណើរ ឬក៏រថយន្តជិះដោយសារគ្នា ជាមួយលក្ខខណ្ឌដាក់ស្លាកលេខសំរាប់អ្នកសុំគ្នាជិះដែលចេញពីរដ្ឋ ហើយ ក្នុងពេលឆាប់ៗអាចដាក់ពាក្យសុំ ទៅនាយកដ្ឋានដឹកជញ្ជូនវេសស៊ីអាថូ អេសឌីអូធី (SDOT) ដើម្បីទទួលបានការអនុញ្ញាតជិះចូល ស្ពូខេន អេសធី ស្វីងប្រីច(ស្ពានទាប)។

ការអនុញ្ញាឱ្យធ្វើដំណើរនេះ គឺជាគោលការណ៍បណ្តោះអាសន្នដែលមានការកំណត់។

អ្នកដំណើរត្រូវតែដាក់ពាក្យស្នើរសុំ ផ្តល់ឲ្យនូវស្លាកលេខរថយន្ត

បំពេញគ្រប់គ្រាន់នូវរាល់លក្ខខណ្ឌនតម្រូវឲ្យ ព្រមទាំងទទួលការអនុញ្ញាតពីអេសឌីអូធី

(SDOT) មុនពេលប្រើប្រាស់ស្ពានទាប។

អេសឌីអូធី(SDOT) ថែមទាំងផ្លាស់ប្តូរម៉ោងដាក់បំរាម

គឺដើម្បីអាចឲ្យអ្នកគ្រប់គ្នាអាចជិះចូលច្រើនេជាងមុននៅចុងសប្តាហ៍។

ព័ត៌មានចរាចរណ៍ថ្មីៗនេះបានបង្ហាញថាចំនួនដែលបានជិះចូល

មានតិចតួចដូច្នេះអាចអនុញ្ញាតឲ្យមានការជិះចូលបន្ថែម។

ស្ពានទាបថ្មីៗនេះបានបិទសំរាប់យានយន្តដែលគ្មានការអនុញ្ញាតឲ្យចូលចាប់ពីម៉ោង

៥ព្រឹកដល់ម៉ោង ៩យប់ជារៀងរាល់ថ្ងៃ។ ចាប់ពីថ្ងៃសៅរ៍ទី១០ខែមេសា

ស្ពានទាបនិងបើកសំរាប់អ្នកគ្រប់គ្នា

រយះពេល៣ម៉ោងបន្ថែមរហូតដល់ម៉ោង៨ព្រឹកសំរាប់ថ្ងៃចុងសប្តាហ៍។ សំរាប់ថ្ងៃធ្វើការ

ការដាក់កម្រិត និងនៅតែបន្តរដូចពីមុន។
នៅពេលស្ពានអាកាស់ស៊ីអាថូខាងលិច(ស្ពានអាកាស់) បានបិទនៅខែមិនាឆ្នាំ២០២០ អេសឌីអូធី(SDOT)
បានដាក់កម្រិតការជិះចូលពីស្ពានទាបដើម្បីជៀសវាងមានតំបន់ស្ទះចរាចរណ៍នៅ

ផ្លូវរាងទូទៅ។
នៅពេលថ្ងៃការប្រើប្រាស់ស្ពានទាបគឺបានដាក់កម្រិតដើម្បីឲ្យប្រាកដថាឡានកុងទន័រ ឡានដឹកទំនិញផុនផូន់ រថយន្តសង្គ្រោះបន្ទាន់អាចធ្វើដំណើរដោយសេរីទៅមកពីវេសស៊ីអាថូ។ ព័ត៌មានបន្ថែមរួមបញ្ចូលទាំងតារាងដាក់រាយឈ្មោះប្រភេទរថយន្តទាំងឡាយដែលមានគ្រប់លក្ខខណ្ឌទទួលសិទ្ធអាចជិះចូលបានគឺអាចរកបាននៅគេហទំព័ររបស់ស្ពានទាប។
រថយន្តសង្គ្រោះបន្ទាន់ រថយន្តក្រុង
ឡានដឹកទំនិញធុនធំមិនចាំបាច់ឲ្យស្លាកលេខទៅកាន់អេសឌីអូធី(SDOT)ទេ។

## ក្រុមថ្មីដែលមានសិទ្ធសំរាប់ការអនុញ្ញាតទុកជាមុនដើម្បីជិះចូលស្ពានទាប

- ប្រជាជនដែលរស់នៅ ស៊ីអាថូខាងលិច ធ្វើដំណើរទៅមកសំរាប់ការទទួលសេវាព្យាបាលសង្គ្រោះជីវិត (ដែលបានអនុញ្ញាតពីគ្រូពេទ្យខាងថែទាំសុខភាព សំរាប់ទំរង់បែបបទអាចរកបានតាមរយៈគេហទំព័ររបស់ស្ពានទាប)
- ការហៅទូរស័ព្ទទៅកាន់គ្រូពេទ្យប្រចាំការតាមទូរស័ព្ទ (ការធ្វើដំណើរទៅមកក្នុងម៉ោងធ្វើការហៅទូរស័ព្ទប៉ុន្នោះ)
- សំរាប់ភោជនីយដ្ឋាននិងហាងតវ៉ាន់លក់រាយទាំងអស់ (មានកំណត់ការធ្វើដំណើរជាបន្ទាន់ដើម្បីទៅយកគ្រឿងឧបករណ៍ប្រើប្រាស់ឬគ្រឿងផ្គត់ផ្គង់)
- ការសុំគ្នាជិះតាមរថយន្ត (ឡានច្រើនកៅអ៊ី រថយន្តដឹកអ្នកដំណើរ ឬរថយន្តជិះដោយសារគ្នាដែលទទួលស្គាល់ជាផ្លូវការ មានស្លាកលេខសំរាប់សុំគ្នាជិះដែលចេញពីរដ្ឋ ទាំងអស់នេះមិនរួមបញ្ចូលទាំងឡានអឺបឺ/លីវ ទេ

## ក្រុមដែលកំពុងមានសិទ្ធសំរាប់ការអនុញ្ញាតទុកជាមុនដើម្បីជិះចូល

- ក្រុមដែលជាសមាជិកតំបន់ឡូងហ័រអន្តរជាតិនិងសហជីពឃ្លាំងក្នុងស្រុកមានសមាជិកចំនួន ១៩ នាក់សម្រាប់ការធ្វើដំណើរនៅពេលមានការបញ្ជូន(ដូរវេនគ្នា) ពីសាលសហជីពអេសអូឌីអូ រហូតដល់ស្ថានីយចំណតនៅខាងលិចនៃស្ពានទាប
- ពួកអ្នកដើសមុទ្រ និងក្រុមអាជីវកម្មឧស្សាហកម្មនៅជិតស្ពានទាប (កំណត់ចំពោះការធ្វើដំណើរជាបន្ទាន់ដើម្បីយកឧបករណ៍ប្រើប្រាស់ឬ គ្រឿងផ្គត់ផ្គង់ ឬអ្នកដឹកជញ្ជូនសំខាន់ៗ)

យានយន្តរបស់រាជរដ្ឋាភិបាល( ត្រូវបានគេកំណត់សំរាប់ការធ្វើដំណើរបន្ទាន់/ការធ្វើដំណើរដោយមិនបានត្រៀមទុកមុន និងរួមបញ្ចូលទាំងទីក្រុងស៊ីអាថូ ឃីងខោនធី និងរដ្ឋវ៉ាស៊ីងតោន អ្នកអនុវត្តច្បាប់ក្នុងតំបន់ និងយានយន្តរបស់រាជរដ្ឋាភិបាលផ្សេងៗទៀត)។

នៅចុងខែមេសានេះ អេសឌីអូធី(SDOT) និងចែកចាយទំរង់បែបបទតាមអនឡាញសំរាប់ការ ហៅចូលជួបគ្រូពេទ្យប្រចាំការតាមទូរស័ព្ទ អ្នកធ្វើអាជីវកម្ម និងការចែកគ្នាជិះដើម្បីស្នើរសុំជិះចូលស្ពានទាប។

ពាក្យស្នើរសុំសំរាប់អ្នកធ្វើដំណើរទៅមកដើម្បីទទួលសេវាព្យាបាលសង្គ្រោះជីវិតគឺអាចយកតាមអនឡាញថ្ងៃនេះ។
ប្រជាជនដែលចង់បើកបរចូលត្រូវតែចុះឈ្មោះស្លាកលេខរបស់ពួកគេ ហើយបានទទួលការអនុញ្ញាតពីអេសឌីអូធី(SDOT) មុនពេលប្រើប្រាស់ស្ពានទាប។ យានយន្តដែលមិនទាន់ចុះឈ្មោះចូលនិងត្រូវទទួលការផាកពិន័យ៧៥ដុល្លារ រាល់ដងពេលដែលជិះចូលទៅមកពីស្ពានទាបនៅពេលថ្ងៃ។ ពាក្យស្នើរសុំនឹងត្រូវបានដំណើរការដោយផ្អែកលើមូលដ្ឋានរើសតាមលេខរៀង។

**ម៉ោងបន្ថែមសំរាប់ចុងសប្តាហ៍ថ្មីនិងចាប់ផ្តើមនៅថ្ងៃសៅរ៍ទី១០ខែមេសា**
អេសឌីអូធី(SDOT) គឺកំពុងតែធ្វើការផ្លាស់ប្តូរម៉ោងដាក់បំរាមដើម្បីអនុញ្ញាតឲ្យអ្នកគ្រប់គ្នាអាចប្រើប្រាស់ស្ពានទាបសំរាប់៣ម៉ោងបន្ថែមទៀត រហូតដល់ម៉ោង៨ព្រឹក នៅចុងសប្តាហ៍ប៉ុន្នោះ។ អេសឌីអូធី(SDOT) បានត្រួតពិនិត្យម្តងទៀតនូវព័ត៍មានថ្មីៗនេះថា ចំនួនដែលបានជិះចូលគឺតិចតួចក្នុងរយះពេលនេះ ហើយអាចអនុញ្ញាតឲ្យដាក់ចំនួនបន្ថែមទៀតដែលអាចជិះចូលស្ពាននេះបាន។ ការផ្លាស់ប្តូរនេះនិងត្រូវអនុវត្តចាប់ពីសប្តាហ៍នេះ ថ្ងៃសៅរ៍ទី១០ និងថ្ងៃអាទិត្យទី១១ ខែមេសា។ សូមជួយដាស់តឿនរំលឹកថា ស្ពានទាបនិងត្រូវបិទ សំរាប់យានយន្តដែលគ្មានការអនុញ្ញាត **ចាប់ពីម៉ោង៥ព្រឹក ដល់ម៉ោង៩យប់សំរាប់រាល់ថ្ងៃធ្វើការ និងចាប់ពីម៉ោង៨ព្រឹកដល់ម៉ោង៩យប់នៅរាល់ចុងសប្តាហ៍ទាំងអស់** :

- ហាមមិនឲ្យរថយន្តផ្ទាល់ខ្លួន(ឡាន ឡានតូច ឡានជិះដោយសារគ្នា ជាដើម)
- ហាមមិនឲ្យម៉ូតូ និងម៉ូតូស្កូតទ័រជិះចូលទេ
- ហាមមិនឲ្យឡានតាក់ស៊ី និងរថយន្តជិះតាមអេបដូចជា អ៊ីបឺ និងលីវ

**គោលនយោបាយដើម្បីជិះចូលស្ពានទាប**

គោលបំណងរបស់អេសឌីអូធី(SDOT) គឺត្រូវឲ្យប្រាកដថាធ្វើឲ្យមានទំនុកចិត្តសម្រាប់រថយន្តសង្គ្រោះបន្ទាន់ កុងទន័រ និងរថយន្តដឹកទំនិញធុនធ្ងន់អាចជិះចូលស្ពានទាបបាន។ ចាប់តាំងពីការអនុវត្តស្វ័យប្រវត្តិបានចាប់ផ្តើមនៅដើមឆ្នាំ ២០២១ អេសឌីអូធី(SDOT) បានធ្វើការអង្កេតនិងពិនិត្យចំនួនគោលដៅទាំងអស់ ដោយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះគោលនយោបាយដើម្បីជិះចូលស្ពានទាប ដែលបានកំណត់គោលដៅនិងគោលបំណង ហើយនឹងនៅតែបន្តធ្វើការកែសម្រួលគោលនយោបាយនៅពេលមានកាផ្លាស់ប្តូរក្នុងកាលៈទេសៈណាមួយ។

សុខភាពជីវិតនិងសុវត្ថិភាពបានឈានមុខគេក្នុងឆ្នាំកន្លងមកនេះហើយអេសឌីអូធី(SDOT) កំពុងផ្តល់អាទិភាពដល់ការធ្វើដំណើរដែលជួយសំរួលដល់អ្នកជម្ងឺនិងគ្រូពេទ្យខាងថែទាំសុខភាព ដែលអាចឲ្យពួកគាត់អាចជិះចូលទៅមក ដើម្បីទទួលបានការព្យាបាលថែទាំសុខភាពសង្គ្រោះជីវិត។

អេសឌីអូធី(SDOT) បន្តផ្តល់អាទិភាពដល់ការធ្វើដំណើរនៃរថយន្តសង្គ្រោះបន្ទាន់និងរថយន្តរដ្ឋាភិបាលដែលឆ្លើយតបនឹងស្ថានភាពបន្ទាន់។

ជំងឺកូវីត ១៩ និងការបិទស្ពាន វេសស៊ីអាថូ បានជះឥទ្ធិពលដល់ប្រជាជននិងការធ្វើអាជីវកម្មទាំងអស់នៅ វេសស៊ីអាថូ។

អេសឌីអូធី(SDOT) បានផ្តល់ការយកចិត្តទុកដាក់ក្នុងការអនុញ្ញាតឲ្យភោជនីយដ្ឋាននិងអាជីវកម្មលក់រាយអាចជិះចូលបានដោយផ្អែកលើកត្តាជាច្រើន។ រាល់សាជីវកម្មទាំងអស់នេះត្រូវបានរងផលប៉ះពាល់ច្រើនជាងដោយសារជំងឺកូវីត ១៩។

តាមរយៈកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយជាបន្តរបស់អេសឌីអូធី(SDOT) ទីក្រុងក៏កំពុងធ្វើអង្កេតពីការបិទស្ពាន រួមជាមួយជំងឺកូវីត ១៩ ថាបានជះឥទ្ធិពលដល់អាជីវកម្មជាពិសេសក្នុងការទទួលឥវ៉ាន់ ឬដឹកជញ្ជូនការផ្គត់ផ្គង់។

ការធ្វើដំណើរភាគច្រើននៅលើស្ពានទាប (លើកលែងតែរថយន្តសង្គ្រោះបន្ទាន់ ឡានដឹកទំនិញធុនធ្ងន់ និងកុងទន័រ) គឺត្រូវស្ថិតក្នុងគោលបំណងដែលមានលក្ខខណ្ឌនិងទិសដៅធ្វើដំណើរ (ចំនួនដងនៃការធ្វើដំណើរដែលត្រូវបានអនុញ្ញាតក្នុងមួយខែ) នឹងត្រូវបានធ្វើបច្ចុប្បន្នភាពផ្អែកលើការប្រើប្រាស់ជាក់ស្តែង។ អេសឌីអូធី(SDOT) អាចដាក់កម្រិតឬដកហូតសិទ្ធិជិះចូលប្រើនៅពេលណាក៏បានដែល។ អេសឌីអូធី(SDOT) នឹងជូនដំណឹងដល់ប្រជាជនទុកជាមុនប្រសិនបើមានករណីបែបនេះ។ អេសឌីអូធី(SDOT) នឹងកាត់បន្ថយឬដកហូតសិទ្ធក្នុងការប្រើប្រាស់ស្ពានទាបរបស់ក្រុមជាច្រើនទៀតនៅចុងឆ្នាំ ២០២១នេះ មុនពេលចំណតកំពង់ផែស៊ីអាថូលេខ៥ ចាប់បើកជាថ្មី ដូច្នេះស្ពានអាចបង្កើនចំនួនជិះចូលបន្ថែមសំរាប់ ចរាចរណ៍ដឹកទំនិញរថយន្តធុនធ្ងន់ ។ ស្ពានអាកាស់ត្រូវបានគេរំពឹងថានឹងបើកដំណើរការឡើងវិញនៅពាក់កណ្តាលឆ្នាំ ២០២២ ។

###

បកប្រែដោយ : រ័ត្ន ឥន្ទ ហេមប៊ិច(Roth En Hamberg)